Australian Volunteers

# បុគ្គលគ្រប់រូបទទួលខុសត្រូវចំពោះកិច្ចការពារកុមារ

## កម្មវិធីអ្នកស្ម័គ្រចិត្តអូស្ត្រាលីប្តេជ្ញាការពារកុមារពីគ្រោះថ្នាក់ និងការរំលោភបំពានគ្រប់រូបភាព។



ខ្ញុំមានសុវត្ថិភាព នៅពេលដែលខ្ញុំនៅជាមួយគ្រួសាររបស់ខ្ញុំ។
ដោយសារពួកគាត់នៅមើលថែខ្ញុំ*

# សិទ្ធិរបស់ខ្ញុំ




## កុមារមានសិទ្ធិ

កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារពីការរំលោភបំពានរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត និងការកេងប្រវ័ញ្ច។

កុមារគ្រប់រូបមានសិទ្ធិបញ្ចេញមតិ និងគួរឲ្យមានការស្តាប់មតិយោបល់របស់ពួកគេផងដែរ។ សិទ្ធិទាំងនេះ និងសិទ្ធិផ្សេងទៀតត្រូវបានដាក់បញ្ចូលទៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

កម្មវិធីអ្នកស្ម័គ្រចិត្តអូស្ត្រាលីប្តេជ្ញាលើកកម្ពស់សិទ្ធិរបស់កុមារ។ នេះគឺជាការទទួលខុសត្រូវមួយដែលយើងចែករំលែកទៅដល់បុគ្គលិក ដៃគូ និងអ្នកស្ម័គ្រចិត្តរបស់ពួក យើង។

## វិធីសាស្ត្ររបស់ពួកយើងក្នុងកិច្ចការពារកុមារ

ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារអាចកើតមានក្នុងគ្រប់ប្រទេសទាំងអស់ទូទាំងពិភពលោក នៅក្នុងគ្រួសារ សាលារៀន សហគមន៍ និងមជ្ឈដ្ឋានអនឡាញ។

កម្មវិធីនេះប្តេជ្ញាការពារកុមារពីការរំលោភបំពានគ្រប់រូបភាព។ យើងទទួលយកវិធីសាស្ត្រផ្តោតលើកុមារ និងផ្អែកលើសិទ្ធិរបស់កុមារ។

គោលនយោបាយស្តីពីកិច្ចការពារកុមាររបស់ពួកយើងតម្រូវឲ្យបុគ្គលិក អ្នកស្ម័គ្រចិត្ត និងដៃគូរបស់ពួកយើងទាំងអស់មិនត្រូវបង្កគ្រោះថ្នាក់ដល់កុមារ និងធ្វើសកម្មភាពការងារដើម្បីជាឧត្តមប្រយោជន៍ដល់ពួកគេជានិច្ច។

យើងមានគោលការណ៍មិនលើកលែងចំពោះការកេងប្រវ័ញ្ច និងការបង្កគ្រោះថ្នាក់ដល់កុមារ។ យើងនឹងឆ្លើយតបភ្លាមៗជានិច្ចនូវរាល់ហេតុការណ៍ ក្តីកង្វល់ ឬទឡ្ហីករណ៍អំពីគ្រោះថ្នាក់ ឬការមិនអនុលោមតាមគោលនយោបាយរបស់យើង និងត្រូវគិតគូរផលប្រយោជន៍របស់កុមារជាធំ។




## របៀបគាំទ្រដៃគូរបស់ពួកយើង

កិច្ចការពារកុមារគឺជាការទទួលខុសត្រូវរួមគ្នា។

យើងធ្វើការក្នុងភាពជាដៃគូជាមួយអង្គការនានាដើម្បីពង្រឹងគោលនយោបាយ និងប្រព័ន្ធកិច្ចការពារកុមារ និងផ្អែកលើវិធានការសុវត្ថិភាពកុមារដែលមានស្រាប់ ដើម្បីគាំទ្រដល់កិច្ចការពារកុមារ។

ដៃគូនានាទទួលបាន៖

- គាំទ្រក្នុងការបង្កើត និងអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារ
- ធនធានជាក់ស្តែង ដូចជា សៀវភៅកិច្ចការគោលនយោ- បាយស្តីពីកិច្ចការពារកុមារ
- ការណែនាំពីរបៀបរាយការណ៍អំពីហេតុការណ៍ និងបណ្តាញរាយការណ៍សម្ងាត់
- សមាជិកបុគ្គលិកមូលដ្ឋានដែលមានការប្តេជ្ញាចិត្តនៅក្នុងការិយាល័យប្រចាំប្រទេសរបស់អ្នក ត្រូវបានគេស្គាល់ថាជាជនបង្គោលការពារកុមារ
- មានឱកាសចូលរួមក្នុងសិក្ខាសាលា និងទទួលបានការបណ្តុះបណ្តាល

## មានសំណួរដែរឬទេ?

សូមទាក់ទងទៅជនបង្គោលការពារកុមារមូលដ្ឋាននៅក្នុងការិយាល័យប្រចាំប្រទេសរបស់អ្នក។

ចូលទៅកាន់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) តាម៖ unicef.org./child-rights-convention

ទាញយកសៀវភៅកិច្ចការគោលនយោបាយស្តីពីកិច្ចការពារកុមារនៅ: australianvolunteers.com/child-protection

រាយការណ៍អំពីហេតុការណ៍ ឬក្តីកង្វល់ណាមួយដោយផ្ញើសារអេឡិចត្រូនិកទៅកាន់ការិយាល័យប្រចាំប្រទេសរបស់អ្នក ឬតាម៖ childprotection@australianvolunteers.com

australianvolunteers.com

ទំនាក់ទំនងមក៖: childprotection@australianvolunteers.com

សិក្សាបន្ថែមអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ តាមរយៈ៖: unicef.org./child-rights-convention

*រូបភាពផ្អែកលើគំនូរគូរដោយអ្នកទទួលផលជាកុមារនៃ “គម្រោងអប់រំកុមារជាជនភៀសខ្លួន Three2Six” រៀបចំឡើងដោយ Sacred Heart College អាហ្វ្រិកខាងត្បូង។ គម្រោងនេះផ្តល់ការអប់រំ និងការតស៊ូមតិដើម្បីជនភៀសខ្លួនគ្រប់អាយុចូលរៀនបឋមសិក្សា និងកុមារចំណាកស្រុក។

** ទាំងនេះគ្រាន់តែជាសិទ្ធិមួយចំនួនរបស់កុមារប៉ុណ្ណោះ សូមអានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដើម្បីឈ្វេងយល់បន្ថែមទៀត

Australian Volunteers | Australian Aid